# មេរៀនទី ១ ការចាប់ផ្ដើម និងរៀបបញ្ចូលគណនីយ្យ អ៊ីម៉ែល



Microsoft Outlook ជាប្រភេទកម្មវិធីមួយដែលទទួលបានការពេញនិយមយ៉ាងខ្លាំងពីសំណាក់អ្នកប្រើប្រាស់សម្រាប់ធ្វើការផ្ញើរនិងទទួលរាល់សារ Electronic (អ៊ីម៉ែល)។

Microsoft Outlook គឺជាកម្មវិធីមួយក្នុងចំណោមកម្មវិធីរបស់ Microsoft Office និងមានដោយស្វ័យប្រវត្តិបន្ទាប់ពីលោកអ្នកបញ្ចូលកម្មវិធី Microsoft Office ទៅក្នុងកុំព្យូទ័រ។

Microsoft Outlook ពិតជាផ្ដល់លក្ខណៈងាយស្រួលដល់អ្នកប្រើប្រាស់អ៊ីម៉ែល ដែលធ្វើការនៅក្នុងក្រុមហ៊ុនឬស្ថាប័នណាមួយ ពោលគឺយើងចាំបាច់ត្រូវការកម្មវិធីមួយនេះដើម្បីធ្វើការទំនាក់ទំនងគ្នា កំណត់ការងាររឺពេលវេលា ក៏ដូចជាកត់ត្រាកំណត់ហេតុផ្សេងៗផងដែរ។

## 1. ស្វែងយល់អំពីកម្មវិធី Ms. Outlook (Navigate the interface)

នេះជារបៀបចូលប្រើកម្មវិធី Microsoft Outlook 2016

### រៀបទី១

ចុច Start => All Program => Microsoft Office 2016 => Microsoft Outlook 2016




### របៀបទី២

លោកអ្នកក៏ស្វែងរកនៅក្នុង "TYPE here to Search" រួចវាយពាក្យ "Outlook"

